ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ១៦៤/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៩
កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៩ កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី២៣
កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២១ កិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាមេរិក
និងកិច្ចប្រជុំពាក់ព័ន្ធ

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦ តបតាមការអញ្ជើញរបស់**ឯកឧត្តម ហ្វឺឌីណាន់ រ៉ូម៉ូលដេស ម៉ាកូស ជូញៀ** (Ferdinand R. Marcos Jr.) ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៩ កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៩ កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី២៣ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២១ កិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាមេរិក ព្រមទាំងកិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

១. កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៩

កិច្ចប្រជុំកំពូល បានបញ្ជាក់ជាថ្មីនូវដំណើរការអាស៊ានបូកបីជាវេទិកាគន្លឹះសម្រាប់កិច្ចសហប្រតិបត្តិការតំបន់នៅអាស៊ីបូព៌ា ដោយមានអាស៊ានជាកម្លាំងចលករ និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពធន់តំបន់ សមាហរណកម្មសេដ្ឋកិច្ច និងប្រព័ន្ធពាណិជ្ជកម្មពហុភាគីបើកចំហផ្អែកលើច្បាប់។ កិច្ចប្រជុំបានអនុម័តសេចក្តីប្រកាសថ្នាក់ដឹកនាំអាស៊ានបូកបីចំនួន២៖ **ស្តីពីពាណិជ្ជកម្មតាមសមុទ្រនិងការតភ្ជាប់ផ្នែកកស្តុកការកម្ម** និង**ស្តីពីការពង្រឹងថាមពលនិងភាពធន់នៃសន្តិសុខស្បៀងអាហារ**។

នៅក្នុងកិច្ចប្រជុំកំពូលនេះ៖ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការធ្វើឱ្យកាន់តែស៊ីជម្រៅនូវពាណិជ្ជកម្ម និងការវិនិយោគ តាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ តំបន់និងការដំឡើងកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ការពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់តាមរយៈពហុភាគីនីយកម្មនៃគំនិតផ្តួចផ្តើមឈៀងម៉ៃ និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី និងការលើកកម្ពស់សន្តិសុខស្បៀងនិងថាមពល។ **សម្តេចធិបតី** ក៏បានអំពាវនាវការគាំទ្រឱ្យការខិតខំដើម្បីទទួលបានពីប្រទេសបូកបីសម្រាប់បរិវត្តកម្មឌីជីថលអាស៊ាន ជាពិសេសការអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន (DEFA) ដើម្បីផ្តល់អត្ថប្រយោជន៍ដល់សហគ្រាសធុនមីក្រូ-តូច-មធ្យម (MSMEs) និងយុវជន។ ដោយសម្លឹងឆ្ពោះទៅខួបលើកទី៣០ នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី នៅឆ្នាំ២០២៧ **សម្តេចធិបតី** បាន

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

លើកទឹកចិត្តឱ្យមានកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងក្លា ដើម្បីប្រែក្លាយភាពជាដៃគូដ៏យូរអង្វែងនេះឱ្យទៅជាលទ្ធផលជាក់ស្តែង សំដៅពង្រឹងភាពធន់តំបន់ និងលើកកម្ពស់វិបុលភាពរួម។

២. កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៩

កិច្ចប្រជុំបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តក្នុងការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុនឆ្ពោះទៅការរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាព នៅក្នុងតំបន់ ដើម្បីគាំទ្រដល់ការសម្រេចបាននូវអាស៊ាន ២០៤៥៖ អនាគតរួមគ្នា។ ថ្នាក់ដឹកនាំបានស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការអនុវត្តសេចក្តីប្រកាសចក្ខុវិស័យរួមស្តីពីមិត្តភាពនិងសហប្រតិបត្តិការអាស៊ាន-ជប៉ុន៖ ដៃគូដែលជឿទុកចិត្តបាន និងបានអនុម័តសេចក្តីប្រកាសរួមស្តីពីការសម្រេចបាននូវសេដ្ឋកិច្ចប្រកបដោយភាពធន់។

សម្តេចធិបតីនាយករដ្ឋមន្ត្រីបានកោតសរសើរចំពោះជប៉ុនដែលជាដៃគូមួយដ៏គួរឱ្យទុកចិត្តបំផុតរបស់អាស៊ាន ហើយបានលើកឡើងនូវអាទិភាពចំនួនបី រួមមាន ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងដើម្បីរួមចំណែកដល់ស្ថិរភាពនិងសន្តិភាពក្នុងតំបន់ ផ្អែកលើការគោរពគោលការណ៍រួមនៃការប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ មជ្ឈភាពអាស៊ាន ភាពបើកចំហ និងបរិយាបន្ន ការពង្រឹងពាណិជ្ជកម្មនិងការវិនិយោគឱ្យកាន់តែស៊ីជម្រៅ តាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ កិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន និងការដំឡើងកម្រិតកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន និងការវិនិយោគលើធនធានមនុស្ស ជំនាញឌីជីថល ទំនើបកម្មបច្ចេកវិទ្យា និងបញ្ញាសិប្បនិមិត្ត។

៣. កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី២៣

កិច្ចប្រជុំបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ឥណ្ឌា ដើម្បីគាំទ្រដល់អាស៊ានឆ្នាំ២០៤៥៖ អនាគតរួមគ្នា និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃមជ្ឈភាពអាស៊ាន និងយន្តការដឹកនាំដោយអាស៊ាន។ កិច្ចប្រជុំបានអនុម័តសេចក្តីប្រកាសរួមអាស៊ាន-ឥណ្ឌាស្តីពីការត្រៀមបង្ការនិងការគ្រប់គ្រងគ្រោះមហន្តរាយ និងបានស្វាគមន៍ឆ្នាំ២០២៦ជាឆ្នាំអាស៊ាន-ឥណ្ឌាស្តីពីកិច្ចសហប្រតិបត្តិការលម្ហសមុទ្រ។ ថ្នាក់ដឹកនាំក៏ទន្ទឹងរង់ចាំការប្រារព្ធខួបលើកទី៣៥នៃទំនាក់ទំនងអាស៊ាន-ឥណ្ឌា នៅឆ្នាំ២០២៧។

សម្តេចធិបតីនាយករដ្ឋមន្ត្រីបានសម្តែងការកោតសរសើរចំពោះការប្តេជ្ញាចិត្តឥតងាករេរបស់ឥណ្ឌាចំពោះអាស៊ាន និងបានចាត់ទុកឥណ្ឌាជារដ្ឋតភ្ជាប់រវាងបណ្តាប្រទេសលោកខាងត្បូង (Global South)។ **សម្តេចធិបតី**បានគូសបញ្ជាក់នូវអាទិភាពចំនួន៥ រួមមាន ការពង្រឹងពាណិជ្ជកម្មនិងវិនិយោគ រួមទាំងការពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា ការអភិវឌ្ឍខ្សែច្រវាក់ផ្គត់ផ្គង់បន្ទះឈីបប្រកបដោយភាពធន់ ការធ្វើឱ្យកាន់តែស៊ីជម្រៅនៃកិច្ចសហប្រតិបត្តិការលើវិស័យបញ្ញាសិប្បនិមិត្តនិងបច្ចេកវិទ្យាឌីជីថល ការលើកកម្ពស់វិទ្យាសាស្ត្រ ការអប់រំ និងការអភិវឌ្ឍជំនាញ និងការលើកកម្ពស់វិស័យទេសចរណ៍និងការតភ្ជាប់ផ្នែកអាកាសចរណ៍។ **សម្តេចធិបតី**ក៏បានទទួលស្គាល់ចំពោះការរួមចំណែករបស់ឥណ្ឌាក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌របស់កម្ពុជា និងបានស្វាគមន៍ចំពោះការដាក់ឱ្យដំណើរការជើងហោះហើរត្រង់របស់ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជារវាងរាជធានីភ្នំពេញ និងទីក្រុងញូវដែលី។

៤. កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២១

កិច្ចប្រជុំបានអះអាងជាថ្មីនូវកិច្ចប្រជុំកំពូលអាស៊ីបូព៌ាជាវេទិការបស់ថ្នាក់ដឹកនាំកំពូលសម្រាប់កិច្ចសន្ទនាយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការ ដោយមានអាស៊ានជាស្នូល។ ប្រមុខដឹកនាំបានសង្កត់ធ្ងន់លើមជ្ឈភាពអាស៊ាន និម្មាបនកម្មតំបន់ដែលបើកចំហ បរិយាបន្ន និងផ្អែកលើច្បាប់ និងការដោះស្រាយវិវាទដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ។ ប្រមុខដឹកនាំ ក៏បានបញ្ជាក់ជាថ្មីអំពីភាពជាសារវន្តនៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ក្នុងឱកាសខួបលើកទី៥០ នៃសន្ធិសញ្ញានេះ។ កិច្ចប្រជុំបានអនុម័តសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាស្តីពីដំណើរឆ្ពោះទៅអនាគតរួមគ្នា៖ ស្ថិរភាព និងការស្តារឡើងវិញ និងសេចក្តីប្រកាសប្រមុខដឹកនាំកិច្ចប្រជុំកំពូលអាស៊ីបូព៌ាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងបទល្មើសពាក់ព័ន្ធ។

នៅក្នុងបទអន្តរាគមន៍ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអំពាវនាវឱ្យភាគីថៃធ្វើការជាមួយកម្ពុជា ដើម្បីដំណើរការឡើងវិញភ្លាមៗនៃការងារវាស់វែងនិងការកំណត់ខណ្ឌសីមាព្រំដែន ដោយគណៈកម្មការព្រំដែនរួម (JBC) ស្របតាមសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ និងសេចក្តីប្រកាសរួមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ក្នុងគោលបំណងសម្រេចបាននូវសន្តិភាពយូរអង្វែងរវាងប្រទេសទាំងពីរ។

សម្តេចធិបតី បានសង្កត់ធ្ងន់ថា បទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាគឺជាការគំរាមកំហែងឆ្លងដែនដ៏ធ្ងន់ធ្ងរដែលទាមទារឱ្យមានកិច្ចសហការរួមគ្នា ហើយមិនគួរត្រូវបានយកទៅប្រើប្រាស់ជាឧបករណ៍ដោយប្រទេសមួយប្រឆាំងទៅនឹងប្រទេសមួយទៀតឡើយ។ **សម្តេចធិបតី**បានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ដោយបានលើកឡើងអំពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (CCOS) ក្រោមការដឹកនាំផ្ទាល់របស់**សម្តេចធិបតី** ការដាក់អនុម័តច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការបង្ក្រាបដោយជោគជ័យនូវទីតាំងប្រព្រឹត្តបទល្មើសឆបោកទ្រង់ទ្រាយធំទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ **សម្តេចធិបតី** ក៏បានលើកឡើងអំពីភាពជោគជ័យរបស់កម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នាខែកញ្ញា ឆ្នាំ២០២៦ ជាមួយនឹងការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ ដែលជាសក្ខីកម្មចំពោះដំណោះស្រាយរួមរបស់យើងក្នុងការបំបែកខ្សែច្រវាក់ និងលុបបំបាត់ការឆបោកប្រាស់តាមប្រព័ន្ធបច្ចេកវិទ្យា ក្នុងពេលតែមួយ និងសម្រាប់ទាំងអស់គ្នា។

៥. កិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាម៉េរិក

ថ្នាក់ដឹកនាំអាស៊ាន-សហរដ្ឋអាម៉េរិកបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-សហរដ្ឋអាម៉េរិក និងស្វាគមន៍ចំពោះការអនុម័តផែនការការងារគ្រប់ជ្រុងជ្រោយដើម្បីអនុវត្តសេចក្តីប្រកាសចក្ខុវិស័យរួមរបស់ថ្នាក់ដឹកនាំអាស៊ាន-សហរដ្ឋអាម៉េរិកក្នុងការលើកកម្ពស់អាស៊ាននិងសហរដ្ឋអាម៉េរិកឱ្យកាន់តែខ្លាំងក្លា សុវត្ថិភាព និងវិបុលភាព សម្រាប់ឆ្នាំ២០២៦-២០៣០។ កិច្ចប្រជុំក៏បានអនុម័តសេចក្តីប្រកាសអាស៊ាន-សហរដ្ឋអាម៉េរិកស្តីពីគោលការណ៍ភាពជាដៃគូរវាងរដ្ឋនិងឯកជន១០ចំណុចសម្រាប់ការដោះស្រាយបញ្ហាការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងទន្ទឹងរង់ចាំការប្រារព្ធខួបលើកទី៥០នៃទំនាក់ទំនងដៃគូសន្ធនាអាស៊ាន-សហរដ្ឋអាម៉េរិក និងខួបលើកទី៥នៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-សហរដ្ឋអាម៉េរិក។

៦. កិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត

នៅក្នុង**កិច្ចប្រជុំប្រមុខដឹកនាំនៃសហគមន៍បំភាយឧស្ម័នកម្រិតសូន្យអាស៊ីលើកទី៤៖ សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការយកចិត្តទុកដាក់កាន់តែខ្លាំងរបស់សហគមន៍បំភាយឧស្ម័នកម្រិតសូន្យអាស៊ីលើភាពធន់សេដ្ឋកិច្ច និងថាមពល ដោយបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការជំរុញសកម្មភាពអាកាសធាតុ កំណើនសេដ្ឋកិច្ច និងសន្តិសុខថាមពល ក្រោមគោលការណ៍ «គោលដៅតែមួយ វិធីសាស្ត្រផ្សេងៗ»។ **សម្តេចធិបតី** ក៏បានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមរបស់ប្រទេសជប៉ុនស្តីពីភាពធន់ប្រកពនិងថាមពល រួមទាំងការស្នុកទុកឥន្ធនៈ និងលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការតំបន់កាន់តែជិតស្និទ្ធលើសន្តិសុខថាមពល និងការផ្លើយតបគ្រោះអាសន្ន។

សម្តេចធិបតីបានគូសបញ្ជាក់ពីការវិនិយោគរបស់កម្ពុជាលើថាមពលកកើតឡើងវិញ ការបញ្ចូនចែកចាយអគ្គិសនី និងការស្នុកទុកថាមពល ក៏ដូចជាការរួមចំណែករបស់កម្ពុជាចំពោះបណ្តាញថាមពលអាស៊ាន និងសមាហរណកម្មអគ្គិសនីក្នុងតំបន់។ **សម្តេចធិបតី**ក៏បានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមក្នុងការប្រមូលហិរញ្ញប្បទានអន្តរកាល ការសម្រួលដល់ការផ្ទេរបច្ចេកវិទ្យា និងការពង្រឹងការកសាងសមត្ថភាព ដោយបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យសម្រេចបាននូវអព្យាក្រឹតភាពកាបូននៅត្រឹមឆ្នាំ២០២៥។

នៅឯ**កិច្ចប្រជុំកំពូលមេគង្គ-ជប៉ុនលើកទី១៣៖** ថ្នាក់ដឹកនាំបានពិនិត្យឡើងវិញនូវវឌ្ឍនភាពនិងអាទិភាពនាពេលអនាគតលើវិស័យភាពធន់សេដ្ឋកិច្ច ការតភ្ជាប់ បរិវត្តកម្មឌីជីថល ចីរភាពបរិស្ថាន និងសន្តិសុខមនុស្ស។ ថ្នាក់ដឹកនាំបានអនុម័តសេចក្តីប្រកាសរបស់សហប្រធាននៃកិច្ចប្រជុំ និងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុនឆ្នាំ២០២៤។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះជប៉ុនសម្រាប់ការគាំទ្រដ៏យូរអង្វែង និងបានរំលេចអំពីសារៈសំខាន់នៃការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព ខ្សែច្រវាក់ផ្គត់ផ្គង់ដែលមានភាពធន់ នវានុវត្តន៍ឌីជីថល ការអភិវឌ្ឍធនធានមនុស្ស និងការផ្លាស់ប្តូរវាងយុវជន។ **សម្តេចធិបតី** បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងបានបង្ហាញពីការត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលតួនាទីជាសហប្រធាននៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន នៅឆ្នាំ២០២៧។

ក្នុងឱកាស នៃការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធខាងលើ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ក៏មានជំនួបការងារទ្វេភាគីជាមួយ **ឯកឧត្តម អេនថូនី អាល់បានីស៊ី** (Anthony Albanese) **នាយករដ្ឋមន្ត្រីនៃប្រទេសអូស្ត្រាលី** និង**ឯកឧត្តម ឡរ៉េន វ៉ុង** (Lawrence Wong) **នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសិង្ហបុរី** ដើម្បីពង្រឹងដល់កិច្ចសហប្រតិបត្តិការទ្វេភាគី និងផ្លាស់ប្តូរទស្សនៈលើបញ្ហាដែលមានផលប្រយោជន៍និងកង្វល់រួមទៅវិញទៅមក៕

ថ្ងៃអង្គារ ៨កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦